# ឪពុក និងកូនប្រុសទាំងឡាយ៖ ទំនាក់ទំនងដ៏អស្ចារ្យមួយ

អែលឌើរ អិម រ័សុល បាឡឺដ
នៃកុម្ភនៃពួកសាវកដប់ពីរនាក់

*ឪពុក និងកូនប្រុស អាចដើរតួយ៉ាងសំខាន់មួយ នៅក្នុងការជួយគ្នាទៅវិញទៅមកឱ្យធ្វើជាមនុស្សដ៏ល្អបំផុតតាមដែលយើងអាចធ្វើទៅបាន ។*

វាគឺជាទិដ្ឋភាពដ៏ស្រស់ស្អាត ដើម្បីមើលឃើញឪពុកទាំងអស់គ្នា អង្គុយនៅគៀកនឹងកូនប្រុសរបស់ខ្លួន ដើម្បីស្ដាប់ការបង្រៀនរបស់ព្រះអម្ចាស់ ហើយទទួលដំបូន្មានមកពីអ្នកដែលមានសិទ្ធិអំណាចទូទៅនៃសាសនាចក្រ ។ វាតែងតែជាក្ដីអំណរមួយ ដើម្បីជួបជាមួយនឹងបុរស និងយុវជននៃបព្វជិតភាព ប៉ុន្តែមានអ្វីមួយដែលពិសេស អំពីការមើលឃើញឪពុក និងកូនប្រុសទាំងអស់មានវត្តមាននៅទីនេះជាមួយគ្នា ។ វាគឺជាការរំលឹកដែលមើលឃើញនឹងភ្នែកមួយ អំពីធាតុដ៏មានអានុភាពបំផុតចំនួនពីរនៃទេវវិទ្យារបស់យើងគឺ៖ បព្វជិតភាព និងគ្រួសារ ។ បព្វជិតភាពគឺជាអំណាចដ៏ទេវភាព ដែលគ្រួសារទាំងឡាយត្រូវបានផ្សារភ្ជាប់ជាមួយគ្នាជារៀងរហូត ។ អ្វីៗដែលមាននៅក្នុងដំណឹងល្អ ដែលបានស្ដារឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ រួមទាំង ពិធីបរិសុទ្ធទាំងឡាយនៃព្រះវិហារបរិសុទ្ធ ត្រូវបានផ្ដោតទៅលើក្រុមគ្រួសារអាចមានចំណែកនៅក្នុង គ្រួសារដ៏អស់កល្បជានិច្ចរបស់ព្រះ ។

នៅយប់នេះ ខ្ញុំចង់និយាយទៅកាន់ឪពុក និងកូនប្រុសទាំងឡាយអំពីរបៀបដែលអ្នកនិយាយជាមួយគ្នា ។ គ្មានទំនាក់ទំនងណាផ្សេងទៀត ល្អដូចជាអ្វីដែលអាច និងគួរតែមានរវាងកូនប្រុស និងឪពុករបស់ខ្លួននោះទេ ។ វាអាចជាទំនាក់ ទំនងមួយដែលមានការចិញ្ចឹមបីបាច់ និងអំណរបំផុតនៅក្នុងជីវិត ជាមនុស្សម្នាក់ដែលអាចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើកូនប្រុសឱ្យផ្លាស់ប្រែ និងទៅលើឪពុកឱ្យផ្លាស់ប្រែផងដែរ ។ ឥឡូវ ខ្ញុំដឹងថា យុវជនមួយចំនួនគ្មានឪពុកដើម្បីអ្នកអាច មានការសន្ទនាប្រភេទនេះទេ ។ ហើយបុរសមួយចំនួនទៀតគ្មានកូនប្រុស ឬបានបាត់បង់កូនប្រុសដោយសារគ្រោះថ្នាក់ ឬជំងឺ ។ ប៉ុន្តែអ្វីភាគច្រើនដែលខ្ញុំនិយាយនៅយប់នេះ នឹងអនុវត្តចំពោះឪពុកមា និងលោកតា និងអ្នកដឹកនាំបព្វជិតភាព និងអ្នកណែនាំដទៃទៀត ដែលពេលខ្លះដើរតួជំនួសនៅក្នុងទំនាក់ទំនងឪពុក និងកូនប្រុសដ៏សំខាន់ទាំងនេះ ។

អ្នកឃើញទេ យើងទាំងអស់គ្នាកំពុងធ្វើដំណើរ ។ ឪពុកទាំងឡាយបានធ្វើដំណើរទៅមុនបន្តិចហើយ ប៉ុន្តែគ្មាននរណាម្នាក់ ក្នុងចំណោមពួកយើងបានទៅដល់ទីផ្ដាច់ព្រ័ត្ររបស់យើងនៅឡើយទេ ។ យើងទាំងអស់គ្នាកំពុងស្ថិតនៅក្នុងដំណាក់កាលនៃការផ្លាស់ប្រែទៅជាមនុស្សម្នាក់ដែលយើងនឹងប្រែក្លាយនាថ្ងៃមួយ ។ ឪពុក និងកូនប្រុស អាចដើរតួយ៉ាងសំខាន់មួយ នៅក្នុងការជួយគ្នាទៅវិញទៅមកឱ្យធ្វើជាមនុស្សដ៏ល្អបំផុតតាមដែលយើងអាចធ្វើទៅបាន ។

ខ្ញុំដឹងថាទំនាក់ទំនងឪពុកនិងកូនប្រុសមិនដែលល្អឥតខ្ចោះនោះទេ ប៉ុន្តែអ្វីៗដែលខ្ញុំនឹងឱ្យយោបល់ដល់អ្នកនៅយប់នេះ គឺជាលទ្ធភាព បើសិនជាអ្នកនឹងខិតខំដោយអស់ពីចិត្តដើម្បីធ្វើឱ្យវាកើតមានឡើង ។

យុវជន អ្នកគឺជាមោទនភាព និងសេចក្ដីអំណររបស់ឪពុកអ្នក។ ពួកគាត់មើលឃើញការសន្យានាពេលអនាគតនៅក្នុងខ្លួនអ្នក ហើយពួកគាត់សង្ឃឹមថានឹងធ្វើឱ្យល្អប្រសើរ និងកែលំអខ្លួនពួកគាត់ថែមទៀត។ ភាពជោគជ័យរបស់អ្នកគឺជា សេចក្ដីអំណរចំពោះពួកគាត់។ ការព្រួយបារម្ភ និងបញ្ហាទាំងឡាយរបស់អ្នក គឺជាការព្រួយបារម្ភ និងបញ្ហារបស់ពួកគាត់។

ឪពុក អ្នកគឺជាគំរូនៃភាពជាបុរសដ៏សំខាន់សំរាប់កូនប្រុសរបស់អ្នក។ អ្នកគឺជាអ្នកណែនាំដ៏មានអត្ថន័យបំផុតរបស់ពួកគេ ហើយជឿទេថា អ្នកគឺជាវិរៈបុរសរបស់ពួកគេតាមរបៀបជាច្រើនដែលមិនអាចរាប់អស់បាន។ ពាក្យសំដី និងគំរូរបស់អ្នកមានឥទ្ធិពលយ៉ាងខ្លាំងមួយទៅលើពួកគេ។

យប់នេះ ខ្ញុំចង់ផ្ដល់យោបល់សាមញ្ញចំនួន*បីចំនុច* ទៅដល់យុវជន អំពីរបៀបទាញយកអត្ថប្រយោជន៍ដ៏ពេញលេញ ពីទំនាក់ទំនងរបស់អ្នកជាមួយនឹងឪពុក។ បន្ទាប់មក ខ្ញុំចង់ផ្ដល់យោបល់ចំនួន *បី* ចំនុចដល់ឪពុកអំពីការទាក់ទង និងការទំនាក់ទំនងជាមួយនឹងកូនប្រុសរបស់អ្នក។

ចំពោះអ្នករាល់គ្នាដែលកាន់បព្វជិតភាពអើរ៉ុន ខ្ញុំជឿថា តាមរយៈការធ្វើនូវចំណុចសាមញ្ញទាំងបីនេះ នោះអ្នកអាចធ្វើឱ្យទំនាក់ទំនងរបស់អ្នកជាមួយនឹងឪពុករបស់អ្នកកាន់តែល្អប្រសើរជាងពេលឥឡូវនេះ។

*ទីមួយ* ទុកចិត្តឪពុករបស់អ្នក។ គាត់មិនល្អឥតខ្ចោះទេ ប៉ុន្តែគាត់ស្រឡាញ់អ្នក ហើយនឹងធ្វើនូវអ្វី ដែលគាត់គិតថា អ្នកពេញចិត្តបំផុត។ ដូច្នេះនិយាយទៅកាន់គាត់។ ចែកចាយគំនិត និងអារម្មណ៍របស់អ្នក ការសុបិន និងភាពភ័យខ្លាចរបស់អ្នក។ កាលណាគាត់កាន់តែដឹងច្រើនអំពីជីវិតរបស់អ្នក នោះជាឱកាសកាន់តែល្អ ដែលគាត់ត្រូវតែយល់អំពីការបារម្ភរបស់អ្នក ហើយផ្ដល់ដំបូន្មានល្អដល់អ្នក។ នៅពេលអ្នកដាក់ការទុកចិត្តរបស់អ្នកទៅលើឪពុក នោះគាត់នឹងដឹង អំពីភារកិច្ចនៃការទុកចិត្តនោះ ហើយព្យាយាមកាន់តែខ្លាំង ដើម្បីយល់ និងជួយដល់អ្នក។ ក្នុងនាមជាឪពុករបស់អ្នក គាត់មានសិទ្ធិដើម្បីទទួលការបំផុសគំនិតជំនួសឱ្យអ្នក។ ដំបូន្មានរបស់គាត់ចំពោះអ្នក នឹងក្លាយជាការបង្ហាញដោយ អស់ពីដួងចិត្តរបស់មនុស្សម្នាក់ដែលស្គាល់ និងស្រឡាញ់អ្នក។ ឪពុករបស់អ្នកចង់បានអ្វីៗជាច្រើនសំរាប់អ្នក ដើម្បីឱ្យអ្នកបានសប្បាយរីករាយ និងមានជោគជ័យ ដូច្នេះហេតុអ្វីក៏អ្នកមិនចង់ទុកចិត្តលើមនុស្សម្នាក់ដូចនេះទៅវិញ? ក្មេងប្រុស ទាំងឡាយអើយ ចូរទុកចិត្តឪពុករបស់អ្នក។

*ទីពីរ* ចាប់អារម្មណ៍ទៅលើជីវិតរបស់ឪពុករបស់អ្នក។ ចូរសួរអំពីការងាររបស់គាត់ ចំណាប់អារម្មណ៍របស់គាត់ គោលដៅរបស់គាត់។ តើគាត់បានសម្រេចចិត្តធ្វើនូវការងារដែលគាត់កំពុងធ្វើនេះដោយរបៀបណា? តើគាត់មាន លក្ខណៈយ៉ាងណា នៅពេលគាត់មានអាយុដូចអ្នក? តើគាត់ជួបនឹងម្ដាយរបស់អ្នកដោយរបៀបណា? ហើយនៅពេលអ្នក ដឹងច្រើនអំពីគាត់ នោះអ្នកអាចឃើញថា បទពិសោធន៍ទាំងឡាយរបស់គាត់ជួយអ្នកឱ្យយល់កាន់តែច្បាស់អំពីមូលហេតុ ដែលគាត់ឆ្លើយតបមកនោះ។ ចូរមើលទៅឪពុករបស់អ្នក។ ចូរមើលអំពីរបៀបដែលគាត់ប្រព្រឹត្តចំពោះម្ដាយរបស់អ្នក។ ចូរមើលអំពីរបៀបដែលគាត់ធ្វើកិច្ចការហៅបំរើក្នុងសាសនាចក្ររបស់គាត់។ ចូរមើលរបៀប ដែលគាត់ធ្វើការប្រាស្រ័យទាក់ទងនឹងមនុស្សដទៃ។ អ្នកនឹងភ្ញាក់ផ្អើលចំពោះអ្វីដែលអ្នកដឹងអំពីគាត់ ដោយគ្រាន់តែតាមរយៈការមើល និង ការស្ដាប់គាត់។ ចូរគិតអំពីអ្វីដែលអ្នកមិនដឹងអំពីគាត់ ហើយស្វែងរក។

សេចក្តីស្រឡាញ់ ការសរសើរ និងការយល់ដឹង របស់អ្នកនឹងកើនឡើង ដោយសារតែអ្វីដែលអ្នកដឹងពីគាត់។ ក្មេងប្រុសទាំងឡាយអើយ ចូរចាប់អារម្មណ៍ទៅលើជីវិត របស់ឪពុករបស់អ្នក។

ហើយ *ទីបី* ចូរសុំដំបូន្មានពីឪពុករបស់អ្នក។ តាមភាពស្មោះត្រង់ៈ គាត់ប្រហែលជានឹងផ្តល់ដំបូន្មានរបស់គាត់ដល់អ្នក ទោះជាអ្នកសុំឬក៏មិនសុំក្តី ប៉ុន្តែវានឹងមានប្រសិទ្ធភាពកាន់តែល្អនៅពេលអ្នកសុំ! ចូរសុំដំបូន្មានរបស់គាត់អំពី សកម្មភាពសាសនាចក្រ ថ្នាក់រៀន មិត្តភក្តិ សាលារៀន ការដើរលេងជាគូ កីឡា ឬល្បែងកំសាន្តដទៃទៀត។ ចូរសុំដំបូន្មានរបស់គាត់អំពីការងារក្នុងសាសនាចក្ររបស់អ្នក ការរៀបចំខ្លួនសំរាប់បេសកកម្ម ការសម្រេចចិត្ត ឬការជ្រើសរើសទាំងឡាយដែលអ្នកត្រូវធ្វើ។ គ្មានអ្វីដែលបង្ហាញនូវការគោរពចំពោះមនុស្សដទៃច្រើនដូចជាការសុំ ដំបូន្មានរបស់គាត់ទេ ពីព្រោះថានៅពេលអ្នកសុំដំបូន្មាន នោះអ្នកកំពុងតែនិយាយថាៈ " ខ្ញុំអរគុណចំពោះ អ្វីដែលអ្នកដឹង និងបទពិសោធន៍ដែលអ្នកមាន ហើយខ្ញុំឱ្យតម្លៃដល់គំនិត និងយោបល់របស់អ្នក"។ ទាំងនោះគឺជារឿងល្អបំផុតដែល ឪពុកម្នាក់ចង់ឮពីកូនប្រុសរបស់ខ្លួន។

តាមបទពិសោធន៍របស់ខ្ញុំ ឪពុកដែលត្រូវបានកូនសុំដំបូន្មាន ព្យាយាមដើម្បីផ្តល់ដំបូន្មានល្អ អាចទុកចិត្ត និងមាន ប្រយោជន៍បំផុត។ តាមរយៈការសុំដំបូន្មានពីឪពុករបស់អ្នក នោះអ្នកមិនត្រឹមតែទទួលបានអត្ថប្រយោជន៍ពីការផ្តល់ឱ្យរបស់គាត់ប៉ុណ្ណោះនោះទេ ប៉ុន្តែអ្នកក៏បានផ្តល់ដល់គាត់នូវការលើកទឹកចិត្តបន្ថែមបន្តិចទៀត ដើម្បីព្យាយាមប្រែក្លាយជាឪពុក និងជាបុរសកាន់តែល្អ។ គាត់នឹងគិតកាន់តែយកចិត្តទុកដាក់អំពីអ្វីដែលគាត់នឹងឱ្យជាដំបូន្មាន ហើយគាត់នឹងធ្វើការខិតខំកាន់តែខ្លាំងដើម្បី "ធ្វើនូវអ្វីដែលគាត់និយាយ"។ យុវជនទាំងឡាយ ចូរសុំដំបូន្មានពីឪពុករបស់អ្នក!

មែនហើយ ឪពុកទាំងឡាយ ឥឡូវនេះដល់វេនរបស់អ្នកម្តង។ ចូរនិយាយអំពីរឿងខ្លះដែលអ្នកអាចធ្វើ ដើម្បីបង្កើនទំនាក់ទំនងរបស់អ្នកជាមួយនឹងកូនប្រុស។ អ្នកនឹងកត់សំគាល់ឃើញថា មានទំនាក់ទំនងខ្លះៗរវាងយោបល់ដែលខ្ញុំនឹងផ្តល់ដល់អ្នក និងយោបល់ដែលខ្ញុំទើបតែផ្តល់ទៅដល់កូនៗរបស់អ្នក។ នោះមិនមែនជារឿងចៃដន្យនោះទេ។

*ទីមួយ* ឪពុកទាំងឡាយ ចូរស្តាប់កូនប្រុសរបស់អ្នក--- ស្តាប់ពួកគេដោយយកចិត្តទុកដាក់។ ចូរសួរសំណួរត្រឹមត្រូវ ហើយស្តាប់នូវអ្វីដែលកូនប្រុសរបស់អ្នកត្រូវនិយាយរាល់ពេលដែលអ្នកនៅជាមួយគ្នាក្នុងពេលពីរបីនាទីនោះ។ អ្នកចាំបាច់ត្រូវដឹង---កុំស្មានប៉ុន្តែត្រូវដឹង---នូវអ្វីដែលកំពុងតែកើតមាននៅក្នុងជីវិតរបស់កូនប្រុសអ្នក។ ចូរកុំស្មានថា អ្នកដឹងអំពីអារម្មណ៍ របស់កូនដោយសារអ្នកធ្លាប់ក្មេងនោះឡើយ។ កូនប្រុសរបស់អ្នករស់នៅក្នុងពិភពលោកមួយខុសប្លែកពីពិភពលោក ដែលអ្នកធំឡើង។ នៅពេលពួកគេចែកចាយជាមួយអ្នក នូវអ្វីដែលកើតឡើង អ្នកត្រូវតែស្តាប់ដោយយកចិត្តទុកដាក់ ហើយកុំវិនិច្ឆ័យឡើយ ដើម្បីអ្នកដឹងនូវអ្វីដែលពួកគេកំពុងតែគិត និងជួបប្រទះ។

ចូរស្វែងរកវិធីដ៏ល្អបំផុតផ្ទាល់ខ្លួនរបស់អ្នកដើម្បីទំនាក់ទំនងនឹងគ្នា។ ឪពុកមួយចំនួន ចូលចិត្តនាំកូនប្រុសរបស់គេទៅស្ទូចត្រី ឬទៅមើលកីឡា។ អ្នកដទៃទៀតចូលចិត្តនិយាយគ្នាដោយស្ងាត់ស្ងៀម ឬធ្វើការជាមួយគ្នានៅទីធ្លាស្មៅ។ ខ្លះទៀត រកឃើញថាកូនរបស់គេចូលចិត្តសន្ទនានៅពេលយប់ មុនពេលចូលគេង។ ចូរធ្វើអ្វីដែលមានដំណើរការល្អបំផុតសំរាប់អ្នក។ ទំនាក់ទំនងដោយផ្ទាល់

ម្នាក់និងម្នាក់ គួរតែមានចំណែកជាទៀងទាត់ក្នុងកាតព្វកិច្ចរបស់អ្នកជាមួយនឹងកូនប្រុស។ ឪពុកគ្រប់រូបចាំបាច់ត្រូវផ្តោតយកចិត្តទុកដាក់ យ៉ាងហោចណាស់ទៅលើគុណភាពនៃការសន្ទនាជាមួយនឹងកូនប្រុសរបស់ គាត់ជារៀងរាល់ខែ អំឡុងពេលពួកគេនិយាយអំពីរឿងជាក់លាក់មួយចំនួនដូចជា សាលារៀន មិត្តភក្តិ អារម្មណ៍ ល្បែងវីដេអូ ការផ្ញើសារ ភាពសក្តិសម សេចក្តីជំនឿ និងទីបន្ទាល់។ ទីកន្លែង ឬពេលវេលា ដែលរឿងនេះកើតឡើង មិនសូវសំខាន់ ដូចជាការពិតដែលវាបានកើតឡើងនោះទេ។

ហើយតើឪពុកចាំបាច់ត្រូវស្តាប់តាមរបៀបណា។ ចូរចងចាំថា ការសន្ទនាដែលអ្នកត្រូវនិយាយដល់ទៅ 90 ភាគរយ គឺមិនមែនជាការសន្ទនាទេ។ ចូរប្រើពាក្យ "អារម្មណ៍" ឱ្យបានច្រើនតាមដែលអ្នកមានអារម្មណ៍ល្អ នៅក្នុង ការពិភាក្សារបស់អ្នកជាមួយនឹងកូនប្រុស។ ចូរសួរថា : "តើកូនមានអារម្មណ៍យ៉ាងណាអំពីអ្វីដែលកូនបានរៀននៅក្នុងថ្នាក់នោះ? តើកូនមានអារម្មណ៍យ៉ាងណាអំពីអ្វីដែលមិត្តភក្តិរបស់កូននិយាយ? តើកូនមានអារម្មណ៍យ៉ាងណា អំពីបព្វជិតភាពរបស់កូន និងសាសនាចក្រ?" ចូរកុំគិតថាអ្នកត្រូវតែព្យាយាមជួសជុល ឬដោះស្រាយអ្វីៗទាំងអស់ អំឡុងពេលជួបគ្នាទាំងនេះនោះឡើយ។ ភាគច្រើនបំផុត រឿងដ៏ល្អបំផុតដែលអ្នកអាចធ្វើគឺគ្រាន់តែស្តាប់ប៉ុណ្ណោះ។ ឪពុកដែលស្តាប់ច្រើនជាងនិយាយ រកឃើញថាកូនប្រុស របស់ពួកគាត់ចែកចាយច្រើនអំពីអ្វីដែលកំពុងតែកើតឡើងពិត នៅក្នុងជីវិតរស់នៅរបស់ពួកគេ។ ឪពុកទាំងឡាយ ចូរស្តាប់កូនប្រុសរបស់អ្នក។

*ទីពីរ* អធិស្ឋានជាមួយ និងសំរាប់កូនប្រុសរបស់អ្នក។ ចូរផ្តល់ពរជ័យបព្វជិតភាពដល់ពួកគេ។ កូនប្រុសដែលមានការ ព្រួយបារម្ភអំពីការប្រលងធំ ឬព្រឹត្តការណ៍ពិសេស នឹងទទួលផលប្រយោជន៍យ៉ាងពិតមកពីពរជ័យបព្វជិតភាពរបស់ឪពុក។ ឱកាសមានដូចជាការចាប់ផ្តើមឆ្នាំសិក្សាថ្មី ថ្ងៃខួបកំណើត ឬនៅពេលគាត់កំពុងតែដើរលេងជាគូ អាចជាឱកាសល្អ ដើម្បីទូលទៅព្រះអម្ចាស់ ដើម្បីប្រទានពរដល់កូនប្រុសរបស់អ្នក។ ការអធិស្ឋាន និងការចែកចាយ ទីបន្ទាល់តែពីរនាក់ អាចនាំអ្នកឱ្យខិតទៅកាន់តែជិតគ្នា ក៏ដូចជាខិតទៅកាន់តែជិតព្រះអម្ចាស់។

ខ្ញុំបានដឹងថា ឪពុកជាច្រើនរងទុក្ខឈឺចាប់ក្នុងចិត្ត ដែលកូនប្រុសបានវង្វេងចេញ ហើយត្រូវបានជាប់អន្ទាក់លោកិយ ដូចជាអាលម៉ា និងម៉ូសាយ បានព្រួយបារម្ភអំពីកូនប្រុសរបស់ពួកគាត់ផងដែរ។ ចូរបន្តធ្វើអ្វីៗគ្រប់យ៉ាងតាមដែលអ្នកអាចធ្វើបាន ដើម្បីរក្សាទំនាក់ទំនងគ្រួសាររឹងមាំ។ ចូរកុំបោះបង់ចោលនូវការអធិស្ឋានដ៏ក្លៀវក្លាជំនួសពួកគេឱ្យអស់ ពីលទ្ធភាពរបស់អ្នកឡើយ។ កូនប្រុសដ៏មានតម្លៃរបស់អ្នកទាំងនេះ គឺជាកូនប្រុសរបស់អ្នកជារៀងរហូត! ឪពុកទាំងឡាយ ចូរអធិស្ឋានជាមួយ និងប្រទានពរដល់កូនប្រុសរបស់អ្នក។

*ទីបី* ហាន "និយាយរឿងសំខាន់ៗ" ជាមួយកូនប្រុសរបស់អ្នក។ អ្នកដឹងអំពីអ្វីដែលខ្ញុំចង់មានន័យហើយ ដូចជា: និយាយអំពីគ្រឿងញៀន និងការផឹកស្រា និយាយអំពីគ្រោះថ្នាក់មកពីប្រព័ន្ធផ្សព្វផ្សាយនៅសព្វថ្ងៃនេះ--- អ៊ិនធើរណែត បច្ចេកវិទ្យាកុំព្យូទ័រ និងរូបអាសគ្រាម--- និងនិយាយអំពីភាពសក្តិសមនៃបព្វជិតភាព ការគោរពដល់ស្ត្រីភេទ និងភាពស្អាតស្អំខាងសីលធម៌។ ខណៈដែលរឿងទាំងនេះ មិនមែនជាប្រធានបទតែមួយគត់ ដែលអ្នកនិយាយជាមួយនឹងកូនប្រុសនោះ សូមកុំគេចវេសពីរឿងទាំងនេះឡើយ។ កូនប្រុសរបស់អ្នកត្រូវការដំបូន្មាន ការណែនាំ និងការផ្តល់គំនិតរបស់អ្នកអំពីប្រធានបទទាំងនេះ។ នៅពេលអ្នកនិយាយអំពីរឿងសំខាន់បំផុតទាំងនេះ អ្នកនឹងរកឃើញថា ទំនុកចិត្តរវាងអ្នកទាំងពីរនឹងរីកចំរើនឡើង។

ជាពិសេសខ្ញុំព្រួយបារម្ភខ្លាចថា យើងធ្វើការទំនាក់ទំនងដោយបើកចំហ និងច្បាស់លាស់ពេក ជាមួយកូនប្រុសរបស់យើងអំពីរឿងផ្លូវភេទ។ កូនប្រុសរបស់អ្នកកំពុងតែធំលូតលាស់នៅក្នុងពិភពលោកមួយ ដែលទទួលយកដោយបើករឿងផ្លូវភេទចំហ ហើយមនុស្សវ័យក្មេងជាប់ទាក់ទងដោយសម្ងៃង ជារឿងធម្មតា និងជារឿងដែលពួកគេមិនគិតថា សំខាន់ត្រូវជៀសវាងទេ។ កូនប្រុសរបស់អ្នកមិនអាចជៀសវាងដោយងាយពីការមើលឃើញជាក់ស្តែងនូវរូបភាព ឯកសារ និងការល្បួងទាក់ទាញខាងផ្លូវភេទដែលមាននៅជុំវិញពួកគេនោះទេ។ ឪពុក និងពួកអ្នកដឹកនាំសាសនាចក្រ ទាំងឡាយ ចាំបាច់ត្រូវមានការពិភាក្សាដោយបើកចំហរ និងជាញឹកញាប់ ដើម្បីបង្រៀន និងបញ្ជាក់ឱ្យច្បាស់អំពីរបៀប ដែលយុវជន នៃបព្វជិតភាពអាចទប់ទល់នឹងរឿងនេះ។ ត្រូវវិជ្ជមានអំពីរបៀបដែលភាពស្និទស្នាលខាងរូបកាយដ៏ស្រស់ ស្អាត និងអស្ចារ្យ អាចមាន នៅពេលវាកើតឡើងនៅក្នុងចំណងដែលព្រះអម្ចាស់បានដាក់ រួមមានទាំងសេចក្តីសញ្ញាក្នុង ព្រះវិហារបរិសុទ្ធ និងការតាំងចិត្តនៃអាពាហ៍ពិពាហ៍ដ៏អស់កល្បជានិច្ច។ តាមការសិក្សាបង្ហាញឱ្យឃើញថា ភាពញញើត ចំពោះសកម្មភាពផ្លូវភេទជាធម្មតា គឺជាអាកប្បកិរិយាល្អ ដែលទាក់ទងនឹងទំនាក់ទំនងផ្ទាល់ខ្លួន ព្រមជាមួយនឹងការតាំងចិត្តពិត និងសេចក្តីស្រឡាញ់មានភាពចាស់ទុំ។ ឪពុកទាំងឡាយ បើសិនជាអ្នកមិនទាន់មាន "ការនិយាយសំខាន់" នេះជាមួយនឹងកូនប្រុសរបស់អ្នក សូមធ្វើវា ហើយធ្វើវាឱ្យបានឆាប់រហ័ស។

ឥឡូវ នៅក្នុងការបញ្ចប់ ខ្ញុំចង់និយាយទៅកាន់អ្នកត្រឡប់មកពីផ្សព្វផ្សាយសាសនាទាំងអស់។ អ្វីៗដែលខ្ញុំបាននិយាយ នៅយប់នេះក៏អនុវត្តចំពោះអ្នករាល់គ្នាផងដែរ។ ចូរទុកចិត្តដល់ឪពុករបស់អ្នក។ អ្នកអាចខិតកាន់តែជិតទៅនឹងគាត់ នៅពេលឥឡូវនេះច្រើនជាងពីមុន ដោយមិនគិតថាទំនាក់ទំនងរបស់អ្នកកាលពីមុនបេសកកម្មរបស់អ្នកយ៉ាងណានោះទេ។ អំឡុងពេលពីរបីឆ្នាំបន្ទាប់ទៀត អ្នកនឹងធ្វើការសម្រេចចិត្តសំខាន់បំផុតនៅក្នុងជីវិតរបស់អ្នក។ ព្រមជាមួយ នឹងការអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌របស់អ្នក ដំបូន្មានមកពីឪពុកលើផែនដីរបស់អ្នក អាចជួយអ្នកធ្វើការ សម្រេចចិត្តទាំងនោះ អំពីការសិក្សា ជំរើសអាជីព និងអពាហ៍ពិពាហ៍របស់អ្នក។ ការសម្រេចចិត្តសំខាន់បំផុតដែលអ្នក នឹងធ្វើនៅក្នុងជីវិតនេះគឺជាការសម្រេចចិត្ត ដើម្បីរៀបការនឹងនារីត្រឹមត្រូវនៅក្នុងព្រះវិហារបរិសុទ្ធ! ខណៈពេលដែលគ្មាន នរណាម្នាក់គួរតែប្រញាប់ប្រញាល់នៅក្នុងការសម្រេចចិត្តដ៏សំខាន់នេះទេ អ្នកត្រឡប់មកពីផ្សព្វផ្សាយសាសនាទាំងអស់ គួរតែខិតខំអំពីរឿងនេះ។ ចូរនៅកន្លែងដែលអ្នកអាចជួបនឹងប្រភេទមិត្តត្រឹមត្រូវ។ ហើយដើរលេងជាគូរជាមួយគ្នា។ "ការដើរលេងជាក្រុម" មិនមែនជាវិធី ឬថាគ្រប់គ្រាន់នោះទេ! "ការចែចង់" ហាក់ដូចជាជាសិល្បៈបាត់បង់---ចូរស្វែងរកវាជាថ្មី។ វានឹងមានប្រសិទ្ធភាព! ចូរសួរឪពុករបស់អ្នក--- ពួកគាត់ដឹង! ចូរកុំរសាត់ទៅលើផ្លូវរបស់លោកិយ។ ផ្ទុយទៅវិញ ចូររក្សានូវសច្ចៈធម៌ និងព្រះវិញ្ញាណដែលអ្នករីករាយនៅក្នុងបេសកកម្មរបស់អ្នក។ សាសនាចក្រត្រូវការភាពជាអ្នកដឹកនាំរបស់អ្នកនាពេលអនាគត។

ហើយឪពុកទាំងឡាយ យោបល់ទាំងបីចំណុច ដែលខ្ញុំបានផ្តល់ឱ្យអ្នកកាលពីមុននេះ គឺអនុវត្តទាំងស្រុងចំពោះទំនាក់ទំនងរបស់អ្នកជាមួយនឹងកូនប្រុសដែលត្រឡប់មកពីផ្សព្វផ្សាយសាសនារបស់អ្នក។ ចូរស្តាប់ពួកគេ ហើយទំនាក់ទំនងជាមួយ ពួកគេជាទៀងទាត់ដោយផ្តោតលើការសន្ទនា។ ចូរនិយាយជាមួយពួកគេស៊ីជម្រៅអំពីអារម្មណ៍ និងបំណងប្រាថ្នារបស់ពួកគេ។ ចូរអធិស្ឋានជាមួយពួកគេ ហើយផ្តល់ការប្រសិទ្ធពរដល់ពួកគេ នៅពេលពួកគេប្រឈមមុខនឹងការសម្រេចចិត្តដ៏សំខាន់ៗនៅក្នុងអនាគតរបស់ពួកគេ។

ខ្ញុំមានអំណរគុណចំពោះកូនប្រុស និងកូនប្រសារប្រុសរបស់ខ្ញុំ ដែលបានបង្រៀនដល់ខ្ញុំយ៉ាងច្រើន ហើយនៅពេលនេះខ្ញុំសូមអធិស្ឋានថា ព្រះវរបិតាសួគ៌នឹងប្រទានពរដល់យើងគ្រប់គ្នា ដែលជាឪពុក និងកូនប្រុសទាំងឡាយ ដើម្បីគោរពដល់បព្វជិតភាពរបស់ខ្លួន ហើយដើម្បីឱ្យយើងចេះស្រឡាញ់គ្នាទៅវិញទៅមក ដោយការធ្វើឱ្យទំនាក់ទំនងជាមួយគ្នា ដែលជាអាទិភាពដ៏ធំបំផុត និងអស់កល្បជានិច្ចមួយនៃជីវិតរស់នៅរបស់យើង ។ ខ្ញុំអធិស្ឋានពីកិច្ចការនេះ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។